ជំពូកទី7 ផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថានជាផ្នែកមួយដ៏សំខាន់ក្នុងការតាមដាន និងអង្កេត លើគំរោងដែលមានឥទ្ធិពលមកលើបរិស្ថាន តាមដំណាក់កាលដំណើរការនីមួយៗរបស់គំរោង។ តាមរយៈការតាមដានអង្កេតនេះអាចបញ្ជាក់ឲ្យឃើញនូវសកម្មភាពអនុវត្តន៍នានា និងការគ្រប់គ្រងស្របតាមផែនការគំរោងដែលបានគ្រោងទុកសំរាប់ការពារ និងកាត់បន្ថយហេតុប៉ះពាល់មកលើបរិស្ថាន។ ការរៀបចំគំរោងផែនការគ្រប់គ្រងបរិស្ថាន សំខាន់បំផុតគឺការរៀបចំកម្មវិធីត្រួតពិនិត្យបរិស្ថានតាមដំណាក់កាលអនុវត្តន៍គំរោង ការរៀបចំ ការបូម-ចាក់។ ក្នុងនោះ ក៏មានការចូលរួមពីស្ថាប័នផ្សេងៗ ដូចជាខាងក្រសួង ឬមន្ទីរបរិស្ថាន ធនធានទឹក និងឧតុនិយម ខណ្ឌរដ្ឋបាលជលផល។ល។

ដើម្បីថែរក្សា និងការពារបរិស្ថាន ម្ចាស់គំរោងត្រូវអនុវត្តន៍តាមផែនការគ្រប់គ្រងបរិស្ថានឲ្យបានខ្ជាប់ខ្ជួន។

7.1-ការគ្រប់គ្រងបរិស្ថាន

ដូចបានពិពណ៌នានៅជំពូកទី4ខាងលើ ចំពោះឥទ្ធិពលទៅវិញទៅមករវាងគំរោង និងធនធានធម្មជាតិតែងតែកើតឡើង។ ក្នុងន័យនេះ គំរោងគួរតែមានការិយាល័យបរិស្ថានឬធនធានមនុស្ស ឬអ្នកតំណាងទទួលខុសត្រូវលើការរៀបចំរបាយការណ៍ការអង្កេត និងពិនិត្យក្នុងអំឡុងពេលគំរោងប្រតិបត្តិជាប្រចាំតាមពេលដែលបានកំណត់។ (មានលំអិតក្នុងតារាង 7.1ខាងក្រោម)

ការរៀបចំរបាយការណ៍អង្កេត ពិនិត្យតម្រូវឲ្យមានការចូលរួមផងដែរ ពីអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធរួមមាន មេភូមិ សហគមន៍នេសាទ ក្រសួង ឬមន្ទីរ បរិស្ថាន ធនធានទឹក និងឧតុនិយម ខណ្ឌរដ្ឋបាលជលផល។

ដំណើរការទូទៅនៃការរៀបចំផែនការគ្រប់គ្រងបរិស្ថាននៅតំបន់គំរោងរួមមាន:

-ការប្រមូលទិន្នន័យ និងវិភាគទិន្នន័យ ធ្វើឡើងដោយម្ចាស់គំរោង ឬទីប្រឹក្សាគំរោង

-ការរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ធ្វើឡើងដោយម្ចាស់គំរោង ឬទីប្រឹក្សាគំរោង

-ការទទួលរបាយការណ៍ និងការអនុវត្តន៍ត្រួតពិនិត្យ ផ្តល់យោបល់សំរាប់របាយការណ៍ មានក្រសួង ឬមន្ទីរបរិស្ថាន និងស្ថាប័នដែលពាក់ព័ន្ធ។ ចំពោះគំរោងថវិការៀបចំ និងចាត់ចែងទូទៅលើគំរោងផែនការគ្រប់គ្រងបរិស្ថានគឺអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងពេលគំរោងដំណើការ។

7.2-ការបណ្តុះបណ្តាលពីបញ្ហាបំពុលបរិស្ថាន

ការបណ្តុះបណ្តាលបរិស្ថានជាផ្នែកមួយរួមចំនែកក្នុងការជួយការពារការបំពុលបរិស្ថាន ពេលគំរោងចាប់ប្រតិបត្តិ ពិសេសការបញ្ចេញសំណល់រឹង-រាវ(ការបង្ហូរប្រេងសំណល់) និងការសាយភាយភាគល្អិតៗ ភាគច្រើនទាំងនេះ គំរោងត្រូវមានកម្មវិធីអប់រំចំពោះនិយោជិក និងកម្មករបស់ខ្លួនឲ្យយល់ដឹងពីបញ្ហាបំពុលបរិស្ថាន និងការការារក្សាសោភ័ណ្ឌភាពបរិស្ថាន។

-ការអប់រំចំពោះការគ្រប់គ្រងសំណល់រឹង-រាវ គឺតម្រូវឲ្យមានការប្រុងប្រយ័ត្នពេលមានការបង្ហូរ ផ្ទេរ ឬស្តុកប្រេង ហើយត្រូវចាក់សំណល់ទៅក្នុងធុងដែលបានកំណត់។ ម្យ៉ាងទៀត មិនត្រូវបោះចោលសំណល់អាហារ ថង់ប្លាស្ទិក សំការ: ខូច របស់មិនប្រើប្រាស់ ជាពិសេសរបស់ដែលមិនងាយនឹងបំបែកធាតុដោយសារអតិសុខុមប្រាណចូលទៅសមុទ្រឡើយ

-ការអប់រំលើការបំពុលគុណភាពទឹក គឺការអប់រំឲ្យចេះប្រើប្រាស់គ្រឿងចក្រ-ឧបករណ៍នានាតាមលក្ខណៈបច្ចេកទេស តាមទីតាំង និងពេលវេលាកំណត់។ ម្យ៉ាងទៀត ត្រូវធ្វើការត្រួតពិនិត្យគ្រឿងចក្រ-ឧបករណ៍ទាំងនោះជាប្រចាំ មុននឹងចាប់ផ្តើមដំណើរការ។

7.3-កម្មវិធីត្រួតពិនិត្យបរិស្ថាន

កម្មវិធីត្រួតពិនិត្យបរិស្ថានជាចំណុចសំខាន់ក្នុងការរៀបចំផែនការគ្រប់គ្រងបរិស្ថាន គឺដើម្បីកំណត់ និងប្រៀបធៀបឲ្យដឹងពីហេតុប៉ះពាល់បរិស្ថានសំខាន់ៗ ដែលបានទទួលលទ្ធផលពីការត្រួតពិនិត្យជាក់ស្តែង នៅតាមដំណាក់កាលនីមួយៗ។

តាមរយៈការវាយតំលៃនៅជំពូក6ខាងលើយើញថា គំរោងបូមល្បាប់កក់ ខ្សាច់ដើម្បីបង្កើតឃ្លង និងយកទៅចាក់បំពេញ មានកត្តាប៉ះពាល់បរិស្ថានមួយចំនួនដែលត្រូវយកចិត្តទុកដាក់មកត្រួតពិនិត្យ ដើម្បីចាត់វិធានការទប់ស្កាត់ហេតុប៉ះពាល់បរិស្ថានជាអវិជ្ជមាន នៅពេលដំណើរការគំរោង(ក្នុងដំណាក់កាលប្រតិបត្តិ) និងបញ្ចប់គំរោង។

ការត្រួតពិនិត្យបរិស្ថាន គឺត្រួតពិនិត្យលើទីតាំងដែលមានបញ្ហា ដោយបញ្ហានេះគេអាចស្មានដឹងមុន ហើយធ្វើការវាយតំលៃ និងកាត់បន្ថយ។ ការត្រួតពិនិត្យមានការចូលរួមពីក្រសួង ឬមន្ទីរបរិស្ថាន និងស្ថាប័នដែលពាក់ព័ន្ធ។

ក្នុងការតាមដានត្រួតពិនិត្យបរិស្ថាននេះ គំរោងបង្កើតកម្មវិធីត្រួតពិនិត្យបរិស្ថាន ហើយអនុវត្តការវាស់ពិនិត្យតាមការកំណត់ បន្ទាប់មកប្រមូលទិន្នន័យយកមករៀបចំ ហើយធ្វើការវាយតំលៃលទ្ធផលតាមដាន រួចបង្កើតជារបាយការណ៍តាមដានបរិស្ថានប្រចាំឆ្នាំ។ ក្នុងនោះ ករណីដែលទិន្នន័យប្រមូលបានមានបញ្ហា ឬជាសរុបគំរោងមានបញ្ហានោះ គំរោងនឹងស្វែងរកដំណោះស្រាយជាបន្ទាន់ និងផ្តាកសកម្មភាពមួយរយៈដើម្បីស្វែងរកដំណោះស្រាយមួយ(រូបភាព 7.1)។ ករណីដែលការតាមដានមានការខ្វះចន្លោះ ឬមានការកែប្រែសកម្មភាពគំរោងនោះ គំរោងនឹងធ្វើការកែតម្រូវកម្មវិធីត្រួតពិនិត្យបរិស្ថានឡើងវិញ។

រូបភាព 7.1 លំហូរនៃការតាមដានត្រួតពិនិត្យបរិស្ថាន



តារាង 7.1 កម្មវិធីត្រួតពិនិត្យបរិស្ថាន លើគំរោងបូមល្បាប់ភក់ ខ្សាច់ ដើម្បីបង្កើតឃ្លង និងចាក់នៅតំបន់សេដ្ឋកិច្ចពិសេសកំពត

បញ្ហា	ផលប៉ះពាល់	ការត្រួតពិនិត្យ	ពេលវេលា	កន្លែង	ស្ថាប័នត្រួតពិនិត្យ
ដំណាក់កាលប្រតិបត្តិគំរោង					
ទីតាំងភូមិសាស្ត្រ	-ប៉ះពាល់ ឬខិតទៅជិតតំបន់នេសាទ តំបន់សហគមន៍ និងព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម វាលដាំសាវាយខុសពីទីតាំងកំណត់	-ពិនិត្យលើចំណុចនិយាម(UTM) និងការបោះពោង	-រយៈពេល6ខែម្តង	-ទីតាំងតំបន់គំរោង	-ក្រសួងបរិស្ថាន -ក្រសួងធនធានទឹក និងឧតុនិយម -ខណ្ឌរដ្ឋបាលជលផល -ស្ថាប័នដែលពាក់ព័ន្ធ -អាជ្ញាធរមូលដ្ឋាន
សណ្ឋានបាតសមុទ្រ	-ដោយសណ្ឋានបាតមានលក្ខណៈជ្រៅ -អាចបូមខុសនឹងលក្ខណៈបច្ចេកទេសឃ្លង នាវាចរឯកភាពដោយក្រសួងសាធារណការ និងដឹកជញ្ជូន	-ពិនិត្យការដាក់ពោងសំគាល់ -ពិនិត្យទំហំមុខកាត់ឃ្លង បាតឃ្លង និងជំរៅឃ្លង	-រយៈពេល6ខែម្តង	-ទីតាំងក្នុងតំបន់គំរោង និងក្បែរតំបន់គំរោង	
ចរន្តទឹក	-ចរន្តទឹកកំណត់ទិស និងទំហំនៃការសាយភាយភាគល្អិត -អាចបង្កសំណឹកឆ្នេរនៅចុងខាងត្បូងតំបន់គំរោង	-ពិនិត្យទិស-ល្បឿនទឹក និងទឹកជោរ-ទឹកនាច	-រយៈពេល12ខែម្តង	-ទីតាំងក្នុងតំបន់គំរោង និងក្បែរតំបន់គំរោង	
ប្រព័ន្ធព្រៃក	-ព្រៃកកោះតូច ងាយរងឥទ្ធិពលនៃការសាយភាយខ្សាច់ពីគំរោង -ព្រៃករលួសនឹងត្រូវចាក់លប់បិទមាត់ព្រៃក	-ពិនិត្យស្ថានភាពទឹកព្រៃកកោះតូច និងព្រៃករលួស -ពិនិត្យផ្លូវទឹកពង្វាងទឹកព្រៃករលួស	-រយៈពេល6ខែម្តង	-តាមព្រៃកកោះតូច និងព្រៃករលួស	
គុណភាពទឹក	-គំរោងអាចធ្វើឲ្យគុណភាពទឹកប្រែប្រួល -ការសាយភាយភាគល្អិតអាចប៉ះពាល់ដល់ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម វាលដាំសាវាយ	-ពិនិត្យគុណភាពទឹក -ការទុកដាក់សំណល់រឹង-ការ -បច្ចេកទេស និងឧបករណ៍បូម	-រយៈពេល6ខែម្តង	-ទីតាំងយកសំណាកទឹកដែលរបាយការណ៍បានយក	
ព្រៃកោងកាង	ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម និងវាលដាំ	-ពិនិត្យស្ថានភាពព្រៃកោងកាង	-រយៈពេល6ខែម្តង	-ក្បែរតំបន់ចាក់បំពេញ	

បញ្ហា	ផលប៉ះពាល់	ការត្រួតពិនិត្យ	ពេលវេលា	កន្លែង	ស្ថាប័នត្រួតពិនិត្យ
ស្មៅសមុទ្រ ផ្កាថ្ម ការដាំសាវាយ	សាវាយ ងាយរងនូវការប៉ះពាល់ពីគំរោង	-ពិនិត្យស្ថានភាពស្មៅសមុទ្រ -ពិនិត្យស្ថានភាពផ្កាថ្ម -ពិនិត្យទីតាំងដាំសាវាយ		-នៅមុខតំបន់ចាក់បំពេញ -ទីតាំងផ្កាថ្ម -ទីតាំងដាំសាវាយ	
ពពួកវាវិសត្វសមុទ្រ	ពពួកវាវិសត្វសមុទ្រងាយរងផលប៉ះពាល់ពីគំរោង	-ពិនិត្យវត្តមានប្រភេទវាវិសត្ត	-រយៈពេល6ខែម្តង	-ក្នុង និងក្បែរតំបន់គំរោង	
ឧបករណ៍ និងបច្ចេកទេសប្រើប្រាស់	-ឧបករណ៍ និងបច្ចេកទេសប្រើប្រាស់ក្នុងការបូមអាចបំពុលគុណភាពខ្យល់ ទឹកសំលេង ការសាយភាយកកស	-ពិនិត្យបច្ចេកទេស ឧបករណ៍ និងរបាយការណ៍	-រយៈពេល12ខែម្តង	-ទីតាំងកំពុងដំណើរការបូម និងចាក់នៅក្នុងតំបន់គំរោង	
ចរាចរណ៍ផ្លូវទឹក	-គំរោងអាចធ្វើឲ្យប្រជានេសាទមិនដឹងទីតាំងដែលអាចឆ្លងកាត់	-ពិនិត្យពោងសម្គាល់ផ្លូវឆ្លងកាត់ -លក្ខណៈចរន្តទឹកផ្លូវឆ្លងកាត់	-រយៈពេល6ខែម្តង	- ទីតាំងដែលគំរោងកំណត់	
ជំណាក់កាលបញ្ចប់គំរោង					
សណ្ឋានបាត	-សណ្ឋានបាតមានលក្ខណៈប្រែប្រួលហើយអាចរាក់បាន	-ពិនិត្យទំហំមុខកាត់ឃ្លង បាតឃ្លង និងជំរៅឃ្លង	-រយៈពេល6ខែម្តង	-ទីតាំងក្នុងតំបន់គំរោង និងក្បែរតំបន់គំរោង	-ក្រសួងបរិស្ថាន -ក្រសួងធនធានទឹក និងឧតុនិយម -ស្ថាប័នដែលពាក់ព័ន្ធ
ចរន្តទឹក	-ចរន្តទឹកមានការប្រែប្រួលដោយសណ្ឋានបាតសមុទ្រអាចរាក់ឡើងវិញ	-ពិនិត្យទិស-ល្បឿនទឹក និងទឹកជោរ-ទឹកនាច	-រយៈពេល12ខែម្តង (ខែប្រាំង និងខែវស្សា)	-ទីតាំងក្នុងតំបន់គំរោង និងក្បែរតំបន់គំរោង	